KB PRASAC Bank

ធនាគារ ខេប៊ីប្រាសាក់ ម.ក

លក្ខខណ្ឌនៃការប្រើប្រាស់បណ្ណឥណពន្ធ

Terms and Conditions of Using Debit Card

បោះពុម្ពលើកទី ១

មាតិកា

1. សេចក្តីផ្តើម....1
2. និយមន័យ....1
3. ប្រភេទប័ណ្ណ....2
4. សុពលភាពនៃប័ណ្ណ....2
5. ម៉ោងប្រតិបត្តិការ....2
6. រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់....2
7. ប្រតិបត្តិការលើប័ណ្ណ....2
8. កម្រៃសេវា....3
9. ការកែប្រែអត្រាការប្រាក់ កម្រៃសេវា ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង....3
10. បង្ខាំង ឬ ដោះបង្ខាំងប័ណ្ណ....3
11. ប័ណ្ណសម្រាប់នីតិបុគ្គល....3
12. ប័ណ្ណនិម្មិត....3
13. ការបញ្ឈប់ការប្រើប្រាស់ប័ណ្ណ....4
14. សុវត្ថិភាពនៃការប្រើប្រាស់ប័ណ្ណ....4
    14.1. ការថែរក្សាប័ណ្ណ និងព័ត៌មានប័ណ្ណ៖....4
    14.2. ការថែរក្សាលេខកូដសម្ងាត់ប័ណ្ណ (PIN)៖....4
    14.3. សារបោកបញ្ឆោតតាមរយៈអ៊ីម៉ែល ឬ ទូរស័ព្ទ៖....5
15. សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី....5
16. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់....6
17. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម....7
18. ការដោះស្រាយវិវាទ....7
19. ច្បាប់គ្រប់គ្រង....7
20. វិភាគភាព....7
21. ភាសា....7

1. សេចក្តីផ្តើម

លក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណរបស់ធនាគារ ខេប៊ីប្រាសាក់ ម.ក តទៅហៅថា **«លក្ខខណ្ឌប្រើប្រាស់»** គឺជាកិច្ចព្រមព្រៀងរវាង **លោក-លោកស្រី** ជាមួយ ធនាគារ ខេប៊ីប្រាសាក់ ម.ក តទៅហៅថា **«ខេប៊ីប្រាសាក់»** ទាក់ទងទៅនឹងការប្រើប្រាស់ប័ណ្ណឥណពន្ធ របស់ខេប៊ីប្រាសាក់។

នៅពេល លោក-លោកស្រី **យល់ព្រម** លើការស្នើសុំប្រើប្រាស់ប័ណ្ណ មានន័យថា លោក-លោកស្រី បានអាន បានយល់ និងព្រមអនុវត្តនូវគ្រប់លក្ខខណ្ឌ ដែលមានចែងនៅក្នុងលក្ខខណ្ឌប្រើប្រាស់នេះ។

2. និយមន័យ

❖ លោក-លោកស្រី	៖ សំដៅលើ ម្ចាស់ប័ណ្ណ ដែលបានស្នើសុំប្រើប្រាស់ប័ណ្ណចេញដោយខេប៊ីប្រាសាក់។
❖ ខេប៊ីប្រាសាក់	៖ សំដៅលើ ធនាគារ ខេប៊ីប្រាសាក់ ម.ក ដែលជាអ្នកចេញប័ណ្ណ ជូន លោក-លោកស្រី។
❖ ប័ណ្ណ	៖ សំដៅលើ ប័ណ្ណឥណពន្ធ ដែលចេញដោយ ខេប៊ីប្រាសាក់។
❖ ប័ណ្ណឥណពន្ធ	៖ សំដៅលើ ប័ណ្ណដែលត្រូវបានធ្វើប្រតិបត្តិការហិរញ្ញវត្ថុនានាដោយប្រើប្រាស់ទឹកប្រាក់ផ្ទាល់ខ្លួនរបស់ លោក-លោកស្រី ដែលមាននៅក្នុងគណនី។
❖ ម្ចាស់ប័ណ្ណ	៖ សំដៅលើបុគ្គល ដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ប័ណ្ណឥណពន្ធ ដើម្បីធ្វើប្រតិបត្តិការផ្សេងៗ ដូចជា ទូទាត់ទំនិញ/សេវាកម្ម ដកប្រាក់។ល។
❖ វីសា / VISA	៖ សំដៅដល់ក្រុមហ៊ុន Visa Inc., ដែលជាក្រុមហ៊ុនផ្តល់សេវាទូទាត់តាមប្រព័ន្ធអេឡិកត្រូនិកជុំវិញសាកលលោកជាមួយនឹងប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ ប័ណ្ណ prepaid cards និងប្រភេទប័ណ្ណផ្សេងទៀងដែលមានស្លាកសញ្ញា VISA។
❖ ប័ណ្ណនិម្មិត	៖ ជាប័ណ្ណឥណពន្ធអេឡិចត្រូនិក និងមិនមានរូបរាងជាប័ណ្ណប្លាស្ទិក (មិនអាចកាន់ ឬ ប៉ះបាន) ដោយអតិថិជនអាចធ្វើការបង្កើតបានភ្លាមៗដោយខ្លួនឯងតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (KB PRASAC Mobile) ប្រើប្រាស់ដើម្បីធ្វើការទូទាត់ទំនិញ/សេវាកម្មតាមអនឡាញ (Online) ។ អតិថិជនអាចមើលឃើញនូវព័ត៌មានប័ណ្ណដែលខ្លួនបានបង្កើតរួមមាន៖ លេខប័ណ្ណ លេខកូដ CVV និងកាលបរិច្ឆេទផុតសុពលភាពតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។
❖ លេខកូដសម្ងាត់ (PIN)	៖ សំដៅលើ លេខកូដចំនួន ០៦ខ្ទង់ ប្រើប្រាស់ដើម្បីអនុម័តប្រតិបត្តិការធ្វើតាមរយៈម៉ាស៊ីនអេធីអឹម ម៉ាស៊ីនដាក់ប្រាក់ ម៉ាស៊ីនឆូតកាត និងមធ្យោបាយផ្សេងៗទៀត ទៅតាមការកំណត់ និងដាក់ឱ្យប្រើប្រាស់ដោយខេប៊ីប្រាសាក់។
❖ គណនីទូទាត់	៖ សំដៅលើ គណនីប្រាក់បញ្ញើសន្សំទាំងឡាយណា ដែលអតិថិជនបានស្នើសុំភ្ជាប់ប័ណ្ណដើម្បីប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការ។
❖ ម៉ាស៊ីនអេធីអឹម (ATM) ឬ ម៉ាស៊ីនដាក់ប្រាក់ (CDM)	៖ សំដៅលើ ម៉ាស៊ីនធារីដើរដោយស្វ័យប្រវត្តិ សម្រាប់ឱ្យម្ចាស់ប័ណ្ណ ប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុផ្សេងៗបាន ដូចជា ដកប្រាក់ ដាក់ប្រាក់ ឬ ពិនិត្យសមតុល្យ ឬ ប្រតិបត្តិការផ្សេងៗ។
❖ ម៉ាស៊ីនឆូតកាត (POS)	៖ គឺជាពាក្យកាត់នៃពាក្យ **"Point of Sale"** ដែលជាឧបករណ៍អេឡិចត្រូនិកមួយប្រភេទប្រើប្រាស់សម្រាប់ទទួលការទូទាត់ថ្លៃទំនិញ ឬ សេវាកម្មផ្សេងៗសម្រាប់ពាណិជ្ជករតាមរយៈការស្កេនខេអេចឃ្យូអារកូត (KHQR Code) និងឧបករណ៍ផ្សេងៗទៀតដែលបានអនុញ្ញាតដោយខេប៊ីប្រាសាក់។

3. ប្រភេទបណ្ណ

បណ្ណរបស់ខេប៊ីប្រាសាក់ មានច្រើនប្រភេទទៅតាមការជ្រើសរើសប្រើប្រាស់ពីអតិថិជន រួមមាន៖

ល.រ	បណ្ណឥណពន្ធ (Debit Card)	ការប្រើប្រាស់
1	បណ្ណខេប៊ីប្រាសាក់ (KB PRASAC Card)	ប្រើប្រាស់ក្នុងស្រុក
2	បណ្ណខេប៊ីប្រាសាក់រហ័ស (Instant KB PRASAC Card)	ប្រើប្រាស់ក្នុងស្រុក
3	**បណ្ណឥណពន្ធវីសា (Visa Debit Card)** - បណ្ណក្លាស៊ិក (Classic Card) - បណ្ណហ្គោល (Gold Card) - បណ្ណផ្លាទីនីម (Platinum Card) - បណ្ណអាជីវកម្ម (Business Card)	ប្រើប្រាស់ក្នុងស្រុក និងក្រៅស្រុក
4	បណ្ណនិម្មិត (Virtual Card)	ប្រើប្រាស់ក្នុងស្រុក និងក្រៅស្រុក
5	ប្រភេទបណ្ណផ្សេងៗទៀតដែលនឹងត្រូវដាក់ឱ្យប្រើប្រាស់ដោយខេប៊ីប្រាសាក់ជាបន្តបន្ទាប់ស្របទៅតាមតម្រូវការទីផ្សារ និងលក្ខខណ្ឌអាជីវកម្មជាក់ស្តែង។	

4. សុពលភាពនៃបណ្ណ

4.1. បណ្ណឥណពន្ធ (បណ្ណដែលមានរូបរាង) មានសុពលភាពប្រើប្រាស់រយៈពេល 05ឆ្នាំ។

4.2. លោក-លោកស្រី តម្រូវឱ្យធ្វើការស្នើសុំយ៉ាងតិចមុនរយៈពេល 30ថ្ងៃ នៃថ្ងៃផុតសុពលភាព មក ខេប៊ីប្រាសាក់ ដើម្បីធ្វើការពិនិត្យ និងបោះពុម្ពបណ្ណថ្មី។

5. ម៉ោងប្រតិបត្តិការ

- លោក-លោកស្រី អាចធ្វើប្រតិបត្តិការបណ្ណបានជាប្រចាំថ្ងៃ (24/7) លើកលែងតែមានការផ្អាកប្រតិបត្តិការជាបណ្តោះអាសន្នដោយមានការជូនដំណឹងពី ខេប៊ីប្រាសាក់។

6. រូបិយប័ណ្ណ និងអត្រាប្តូរប្រាក់

6.1. លោក-លោកស្រី អាចធ្វើប្រតិបត្តិការតាមរយៈបណ្ណ ជាមួយ រូបិយប័ណ្ណដុល្លារអាមេរិក (USD) រូបិយប័ណ្ណរៀល (KHR) និងរូបិយប័ណ្ណផ្សេងៗទៀតអាស្រ័យទៅតាមប្រភេទបណ្ណនីមួយៗ។

6.2. រាល់ការធ្វើប្រតិបត្តិការខុសពីរូបិយប័ណ្ណគណនី ត្រូវយោងតាមអត្រាប្តូរប្រាក់ជាក់ស្តែង របស់ ខេប៊ីប្រាសាក់ និង/ឬ ស្ថាប័នទូទាត់អន្តរជាតិវីសា (Visa Inc.)។

7. ប្រតិបត្តិការលើបណ្ណ

7.1. លោក-លោកស្រី អាចប្រើប្រាស់បណ្ណ ដើម្បីធ្វើប្រតិបត្តិការបានគ្រប់ពេល នៅពេលដែលគណនី មានសមតុល្យគ្រប់គ្រាន់ និងត្រូវគោរពទៅតាមទំហំកំណត់ដោយខេប៊ីប្រាសាក់។

7.2. លោក-លោកស្រី ត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់គ្រប់ព័ត៌មាននៃប្រតិបត្តិការឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ មុនពេលសម្រេចអនុម័តប្រតិបត្តិការផ្សេងៗ (ដកប្រាក់ ទូទាត់ទំនិញ-សេវាកម្ម និងទូទាត់តាមរយៈអនឡាញ (Online) ។ល។)

7.3. លោក-លោកស្រី យល់ព្រម បង់កម្រៃសេវាផ្សេងៗ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និង/ឬ ធ្វើប្រតិបត្តិការតាមរយៈបណ្ណ ឬ មធ្យោបាយផ្សេងៗ និងយល់ព្រមឱ្យ **ខេប៊ីប្រាសាក់** ទូទាត់កម្រៃសេវា ដោយផ្ទាល់ចេញពីគណនីរបស់លោក-លោកស្រីដោយស្វ័យប្រវត្តិ។

8. កម្រៃសេវា

- កម្រៃសេវាលើការស្នើសុំប័ណ្ណ កម្រៃសេវាប្រចាំឆ្នាំ ឬ ប្រចាំខែ ការស្នើសុំកែប្រែ/មោឃភាពប័ណ្ណ កម្រៃសេវាលើការធ្វើប្រតិបត្តិការឆ្លងរូបិយប័ណ្ណ និងកម្រៃសេវាលើការធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុផ្សេងៗ (ដកប្រាក់ ដាក់ប្រាក់ ផ្ទេរប្រាក់ ទូទាត់ទំនិញ/សេវាកម្ម បញ្ជូន/បង្វិលទឹកប្រាក់ត្រលប់...) គឺមានបង្ហាញនៅលើវេបសាយត៍ផ្លូវការ និង/ឬ គ្រប់ការិយាល័យខេប៊ីប្រាសាក់។

9. ការកែប្រែអត្រាការប្រាក់ កម្រៃសេវា ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង

9.1. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ អត្រាការប្រាក់ កម្រៃសេវា ទំហំកំណត់ និង/ឬ លក្ខខណ្ឌផ្សេងៗដែលត្រូវអនុវត្តចំពោះការប្រើប្រាស់ប័ណ្ណ របស់ លោក-លោកស្រី ដោយ ខេប៊ីប្រាសាក់ នឹងធ្វើការជូនដំណឹងទៅអតិថិជនឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

9.2. ក្នុងរយៈពេលនៃការជូនដំណឹងខាងលើ ករណីមិនមានការតវ៉ាពី លោក-លោកស្រី ត្រូវសន្មតថា លោក-លោកស្រី បានយល់ព្រម និងទទួលយកការកែប្រែទាំងនោះមកអនុវត្តភ្លាមៗបន្ទាប់ពីការកែប្រែចូលជាធរមានដែលត្រូវបានផ្សព្វផ្សាយតាមរយៈមធ្យោបាយណាមួយខាងក្រោម៖

1). សាខាខេប៊ីប្រាសាក់ និង/ឬ
2). វេបសាយត៍ និង/ឬ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ
3). ការផ្ញើសារ និង/ឬ អ៊ីម៉ែលទៅកាន់ លោក-លោកស្រី
4). ការផ្សព្វផ្សាយនៅលើទំព័រការសែត ទស្សនាវដ្តី កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល សេវាខេប៊ីប្រាសាក់ខបភើរេត ឬ មធ្យោបាយផ្សេងៗ ដែលខេប៊ីប្រាសាក់ បានជ្រើសរើស។ល។

9.3. អតិថិជនត្រូវបានសន្មតថាបានទទួលការជូនដំណឹងស្តីពីការកែប្រែខាងលើភ្លាមៗ បន្ទាប់ពីខេប៊ីប្រាសាក់បានធ្វើការចុះផ្សាយពីការកែប្រែព័ត៌មាននានារបស់ខ្លួនតាមរយៈមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយខាងលើ។

10. បង្ខាំង ឬ ដោះបង្ខាំងប័ណ្ណ

10.1. លោក-លោកស្រី អាចបង្ខាំងប័ណ្ណ (block/freeze) បានភ្លាមៗ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ ស្នើសុំតាមរយៈទូរស័ព្ទ ឬ អ៊ីម៉ែលមកមន្ត្រីទំនាក់ទំនងអតិថិជន (023/086 999 911 / info@kbprasacbank.com.kh) ឬ អញ្ជើញមកកាន់សាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត ឬ មធ្យោបាយផ្សេងៗផ្តល់ដោយខេប៊ីប្រាសាក់។

10.2. លោក-លោកស្រីអាចដោះបង្ខាំង (Unfreeze) ប័ណ្ណបានភ្លាមៗ តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ អញ្ជើញមកសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត ឬ មធ្យោបាយផ្សេងៗផ្តល់ដោយខេប៊ីប្រាសាក់។

11. ប័ណ្ណសម្រាប់នីតិបុគ្គល

11.1. ក្រុមហ៊ុន អង្គការ សមាគម និងស្ថាប័នផ្សេងៗ អាចស្នើសុំប្រើប្រាស់ប័ណ្ណ និងត្រូវទទួលខុសត្រូវចំពោះបំណុល និងប្រតិបត្តិការដែលកើតឡើងដោយអ្នកប្រើប្រាស់ប័ណ្ណ។

11.2. លោក-លោកស្រី ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ភ្លាមៗ ប្រសិនបើមានការផ្លាស់ប្តូរអ្នកប្រើប្រាស់ប័ណ្ណ ដើម្បីឱ្យធនាគារធ្វើការអនុវត្តតាមនីតិវិធី។

12. ប័ណ្ណនិម្មិត

12.1. អតិថិជនអាចធ្វើការបង្កើតប័ណ្ណនិម្មិត ដែលជាប័ណ្ណឥណពន្ធ បានដោយខ្លួនឯងតាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល» និងអាចកំណត់ទំហំទឹកប្រាក់ដើម្បីប្រើប្រាស់ប័ណ្ណប្រចាំថ្ងៃ។

12.2. ករណីមានកម្រៃសេវា អតិថិជនយល់ព្រមបង់កម្រៃសេវាលើការបង្កើតប័ណ្ណនិម្មិត និងអនុញ្ញាតឱ្យខេប៊ីប្រាសាក់ធ្វើការទូទាត់កម្រៃសេវាចេញពីគណនីទូទាត់ភ្ជាប់ប័ណ្ណ។

12.3. អតិថិជនអាចប្រើប្រាស់ប័ណ្ណនិម្មិតសម្រាប់ការទូទាត់ទិញទំនិញ/សេវាកម្មអនឡាញ បានគ្រប់ពេល និងទីកន្លែង។

12.4. អតិថិជនអាចធ្វើការគ្រប់គ្រងការប្រើប្រាស់ប័ណ្ណនិម្មិតតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

12.5. លក្ខខណ្ឌផ្សេងៗមានបង្ហាញលម្អិតនៅក្នុង «លក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណនិម្មិត» ដែលលោក-លោកស្រីអាចស្វែងរក នៅក្នុង កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល និងសាខាណាមួយរបស់ខេប៊ីប្រាសាក់។

13. ការបញ្ឈប់ការប្រើប្រាស់ប័ណ្ណ

- លោក-លោកស្រី អាចស្នើសុំបញ្ឈប់ការប្រើប្រាស់ប័ណ្ណជាលាយលក្ខណ៍អក្សរមកខេប៊ីប្រាសាក់ ឬ តាមមធ្យោបាយផ្សេងៗផ្តល់ដោយខេប៊ីប្រាសាក់។

14. សុវត្ថិភាពនៃការប្រើប្រាស់ប័ណ្ណ

14.1. ការថែរក្សាប័ណ្ណ និងព័ត៌មានប័ណ្ណ៖

14.1.1. សូមរក្សាទុកប័ណ្ណរបស់ លោក-លោកស្រី ឱ្យមានសុវត្ថិភាព។

14.1.2. សូមកុំប្រគល់ ប័ណ្ណ របស់ លោក-លោកស្រី ទៅឱ្យបុគ្គលណាម្នាក់ ដើម្បីយកទៅធ្វើប្រតិបត្តិការជំនួស ជាដាច់ខាត។

14.1.3. សូមកុំយកប័ណ្ណទៅធ្វើប្រតិបត្តិការជាមួយម៉ាស៊ីនអេធីអឹម (ATM) ឬ ម៉ាស៊ីនដាក់ប្រាក់ (CDM) ឬ ម៉ាស៊ីនឆូតកាត (POS) ឬ ប្រព័ន្ធអនឡាញ (Online/E-Commerce) មានភាពសង្ស័យ ឬ មានភាពមិនប្រក្រតី ឬ មិនស្គាល់ច្បាស់ឡើយ។

14.1.4. ត្រូវស្គាល់ និងដឹងពីប្រភេទអាជីវកម្មតាមអនឡាញ និងអាសយដ្ឋានគេហទំព័រ/វេបសាយត៍ដែលទិញទំនិញ/សេវាកម្ម ជាទីគួរឱ្យទុកចិត្តបាន មុនបើកបង្ហាញព័ត៌មានលម្អិតនៃប័ណ្ណ។

14.1.5. សូមកុំផ្តល់ព័ត៌មានប័ណ្ណដូចជា លេខប័ណ្ណ កាលបរិច្ឆេទផុតកំណត់ លេខកូដសម្ងាត់ប័ណ្ណ និង លេខ CVV ដែលមានចំនួន 03ខ្ទង់ (នៅផ្នែកខាងខ្នងប័ណ្ណ) ទៅឱ្យនរណាម្នាក់ជាដាច់ខាត ដោយសារព័ត៌មានទាំងនេះអាចប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការទិញទំនិញ/សេវាបាន។

14.1.6. សូមជូនដំណឹងមកខេប៊ីប្រាសាក់ភ្លាមៗតាមរយៈលេខទូរស័ព្ទ ០២៣/០៨៦ ៩៩៩ ៩១១ ប្រសិនបើ លោក-លោកស្រីសង្ស័យ ឬ កត់សម្គាល់ថា **លេខកូដសម្ងាត់ប័ណ្ណ** ឬ **ព័ត៌មានប័ណ្ណ** ឬ **ប័ណ្ណ** របស់ លោក-លោកស្រីត្រូវបានគេដឹង ឬ ភ្លេច ឬ បាត់ ឬ ត្រូវបានលួច។

14.2. ការថែរក្សាលេខកូដសម្ងាត់ប័ណ្ណ (PIN)៖

14.2.1. សូមធ្វើការផ្លាស់ប្តូរលេខកូដសម្ងាត់ប័ណ្ណ (PIN) នៅពេលទទួលបាន និងបំផ្លាញឯកសារដែលមានព័ត៌មានទាក់ទងនឹងលេខកូដសម្ងាត់នេះចោលភ្លាមៗ។

14.2.2. សូមចងចាំលេខកូដសម្ងាត់ប័ណ្ណ (PIN) ហើយកុំកត់ត្រាលើអ្វីមួយ ឬ ឱ្យអ្នកដទៃដឹង។

14.2.3. សូមកុំផ្តល់ ឬ ផ្ញើលេខប័ណ្ណ និង/ឬ លេខកូដសម្ងាត់ប័ណ្ណ (PIN) ឬ ព័ត៌មានប័ណ្ណ ឬ ព័ត៌មានគណនី ដល់នរណាម្នាក់ ទោះដោយផ្ទាល់មាត់ ឬ សារអេឡិចត្រូនិច អាចជា អ៊ីម៉ែល, Facebook Messenger, Telegram... ជាដើម។

14.2.4. សូមកុំប្រើ ថ្ងៃខែឆ្នាំកំណើត លេខទូរស័ព្ទ លេខគណនី ឬ លេខរៀងដែលងាយស្រួលចាំ ជាលេខកូដសម្ងាត់ប័ណ្ណ។

14.2.5. ត្រូវធានាថា ពេល លោក-លោកស្រី បញ្ចូលលេខកូដសម្ងាត់ (PIN) ដើម្បីប្រើប្រាស់ មិនអាចត្រូវបានឃ្លាំមើលដោយនរណាម្នាក់ ឬ មិនមានមនុស្សនៅក្បែរអ្នកឡើយ។

14.2.6. សូមប្តូរលេខកូដសម្ងាត់ប័ណ្ណ (PIN) ជាប្រចាំ ឬ ក្នុងករណី លោក-លោកស្រី សង្ស័យថា ត្រូវបានដឹងដោយអ្នកដទៃ។

14.3. **សារបោកបញ្ឆោតតាមរយៈអ៊ីម៉ែល ឬ ទូរស័ព្ទ៖**

14.3.1. សូមប្រុងប្រយ័ត្នការបោកបញ្ឆោតយកព័ត៌មាន តាមរយៈអ៊ីម៉ែល វេបសាយ កម្មវិធីដែលលោតផ្ទាំងមក (pop-up Windows) ឬ សារ SMS ដែលជាល្បិចឱ្យលោក-លោកស្រីបញ្ចេញព័ត៌មានសំខាន់ៗ ដូចជា៖ លេខប័ណ្ណ លេខកូដសម្ងាត់ (PIN) លេខកូដ CVV និង កាលបរិច្ឆេទផុតកំណត់ប័ណ្ណ។ល។

14.3.2. ប្រសិនបើ លោក-លោកស្រី ទទួលបានអ៊ីម៉ែល ដែលស្នើសុំព័ត៌មានទាំងនេះ សូមលុបចោលជាបន្ទាន់ និងមិនត្រូវចុចភ្ជាប់បណ្តាញ (Link) ឬ បើកឯកសារភ្ជាប់ណាមួយដែលមាននៅក្នុងអ៊ីម៉ែលនោះឡើយ។

14.3.3. ប្រសិនបើលោក-លោកស្រីមានចម្ងល់ ឬ ក៏មានមន្ទិលសង្ស័យលើវេបសាយ ឬ អ៊ីម៉ែលណាមួយ សូមទំនាក់ទំនងមក ខេប៊ីប្រាសាក់ តាមរយៈ info@kbprasacbank.com.kh ឬ ទូរស័ព្ទលេខ ០២៣/០៨៦ ៩៩៩ ៩១១ ជាបន្ទាន់។

15. សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី

15.1. លោក-លោកស្រី ត្រូវធានាថាគ្រប់ព័ត៌មានដែលបានផ្តល់មក ខេប៊ីប្រាសាក់ ជាព័ត៌មានត្រឹមត្រូវ និង ថ្មីបំផុត។ ករណី លោក-លោកស្រី ផ្តល់ព័ត៌មានមិនពិត ឬ ក្លែងក្លាយ នោះ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់។

15.2. លោក-លោកស្រី ត្រូវធ្វើការត្រួតពិនិត្យកម្រៃសេវា និងព័ត៌មាននៃការទូទាត់ឱ្យបានត្រឹមត្រូវមុននឹងបញ្ជាប្រតិបត្តិការ។ រាល់ការបញ្ចូលព័ត៌មានខុស ឬ សមតុល្យលើស ឬ ខ្វះ ជាដើម ជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

15.3. លោក-លោកស្រី ត្រូវទទួលខុសត្រូវលើការប្រើប្រាស់ប័ណ្ណ និងមិនត្រូវប្រើប្រាស់ប័ណ្ណដើម្បីធ្វើប្រតិបត្តិការក្នុងគោលបំណងមិនស្របច្បាប់ជាតិ និងច្បាប់អន្តរជាតិឡើយ។

15.4. រាល់ការបាត់បង់ទឹកប្រាក់ក្នុងគណនីផ្ទាល់ខ្លួន ឬ គណនីរបស់អ្នកផ្សេង ដែលប្រព្រឹត្តដោយចេតនា ឬ អចេតនា ឬ ដោយការធ្វេសប្រហែស ឬ ដោយការសាកល្បងធ្វើប្រតិបត្តិការផ្សេងៗ ការលុកលុយរុករក ការកែបន្លំទិន្នន័យ ការលួចបន្លំដោយផ្ទាល់ ឬ ដោយប្រយោលតែម្នាក់ឯង ឬ ដោយមានការចូលរួមពីអ្នកដទៃ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

15.5. ក្នុងករណីដែលប័ណ្ណត្រូវបានលួច ឬ បាត់ លោក-លោកស្រីត្រូវជូនដំណឹងមកខេប៊ីប្រាសាក់ជាបន្ទាន់។ លោក-លោកស្រីត្រូវតែទទួលខុសត្រូវចំពោះប្រតិបត្តិការនានា ដែលបានកើតឡើងមុនពេលម្ចាស់ប័ណ្ណជូនដំណឹងមក ខេប៊ីប្រាសាក់អំពីការបាត់ប័ណ្ណ ឬ លួច។

15.6. លោក-លោកស្រី យល់ព្រមដោយឥតលក្ខខណ្ឌក្នុងការទូទាត់សំណងមក ខេប៊ីប្រាសាក់ ករណីមានការប្តឹងតវ៉ា ការទាមទារ ការទទួលខុសត្រូវ ការខាតបង់ ឬ ការចំណាយផ្សេងៗ ដែលខេប៊ីប្រាសាក់ទទួលរងទាក់ទងនឹងប្រតិបត្តិការតាមប័ណ្ណ ដោយការអនុវត្តបំពានរបស់ លោក-លោកស្រី លើលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណ រួមទាំងការខកខានមិនបានចាត់វិធានការទប់ស្កាត់ ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត ឬ ប្រតិបត្តិការក្លែងបន្លំ។ល។

15.7. លោក-លោកស្រី ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាលាយលក្ខណ៍អក្សរឱ្យបានទាន់ពេលវេលា ក្នុងករណីមានការផ្លាស់ប្តូរលេខទូរស័ព្ទ អ៊ីម៉ែល និង/ឬព័ត៌មានផ្ទាល់ខ្លួនផ្សេងៗ ដែលបានផ្តល់មក ខេប៊ីប្រាសាក់។ រាល់ការខាតបង់ ឬ ការពន្យារពេលផ្សេងៗដែលអាចកើតមកពីការខកខានមិនបានជូនដំណឹងមក ខេប៊ីប្រាសាក់ ជាការទទួលខុសត្រូវទាំងស្រុងរបស់ លោក-លោកស្រី។

15.8. លោក-លោកស្រី មិនត្រូវធ្វើប្រតិបត្តិការណាមួយដែលខុសច្បាប់ ឬ សកម្មភាពអាជីវកម្មណាមួយ ដែលត្រូវបានហាមឃាត់ឡើយ។

15.9. លោក-លោកស្រី មានសិទ្ធិក្នុងការផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុង របាយការណ៍គណនី និងសាកសួរមកខេប៊ីប្រាសាក់ ក្នុងករណីមានភាពមិនប្រក្រតីណាមួយកើតឡើង។

15.10. រាល់បញ្ហា ដែលកើតមានឡើងខុសប្រក្រតី ទាក់ទងនឹងសមតុល្យនៅក្នុងគណនី ដែលភ្ជាប់ជាមួយប័ណ្ណ លោក-លោកស្រីត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ឱ្យបានឆាប់រហ័ស។

16. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់

16.1. ខេប៊ីប្រាសាក់ មានសិទ្ធិផ្ទៀងផ្ទាត់ព័ត៌មានរបស់ លោក-លោកស្រី និងសម្រេចក្នុងការផ្តល់ជូនប័ណ្ណដល់ លោក-លោកស្រី។

16.2. ខេប៊ីប្រាសាក់ នឹងអនុវត្តតាមការបញ្ជាលើប្រតិបត្តិការទូទាត់តាមរយៈប័ណ្ណរបស់លោក-លោកស្រី ប៉ុន្តែខេប៊ីប្រាសាក់ មិនទទួលខុសត្រូវ ក្នុងករណីដែល លោក-លោកស្រី បានបញ្ចូលព័ត៌មានខុស ឬ សមតុល្យលើស ឬ ខ្វះ ជាដើម។

16.3. ខេប៊ីប្រាសាក់ មានសិទ្ធិសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត បង្ខាំង ឬ បញ្ឈប់ការប្រើប្រាស់ប័ណ្ណ របស់ លោក-លោកស្រី ដោយយោងលើច្បាប់ ឬ បទបញ្ញត្តិ ឬ ដីកាពីតុលាការ ឬ ការធ្វើប្រតិបត្តិការមិនស្របច្បាប់ណាមួយ។

16.4. ខេប៊ីប្រាសាក់ នឹងរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់ លោក-លោកស្រី លើកលែងមានការយល់ព្រមពី លោក-លោកស្រី ឬ ច្បាប់តម្រូវ ឬ មានដីកាពីតុលាការបង្គាប់ឱ្យបង្ហាញព័ត៌មានសម្ងាត់ទាំងនោះ។

16.5. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកំណត់ចំនួនដង និងចំនួនទឹកប្រាក់ សម្រាប់ការប្រើប្រាស់ប័ណ្ណ។

16.6. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ ឬ អនុវត្តការយកកម្រៃសេវាប្រចាំឆ្នាំ/ប្រចាំខែ និង/ឬ កម្រៃសេវាពាក់ព័ន្ធលើការប្រើប្រាស់ និង/ឬ ធ្វើប្រតិបត្តិការតាមរយៈប័ណ្ណ អាស្រ័យលើលក្ខខណ្ឌ និងស្ថានភាពអាជីវកម្មជាក់ស្តែង។

16.7. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការធ្វើបច្ចុប្បន្នភាពជាប្រចាំលើប័ណ្ណ ដូចជា៖

- ដាក់បន្ថែមនូវមុខងារប្រតិបត្តិការថ្មីៗ ដោយយោងទៅតាមនិន្នាការទីផ្សារ និង/ឬ ការប្រែប្រួលបច្ចេកវិទ្យា ឬ
- លុប ឬ ផ្អាកជាបណ្តោះអាសន្នលើមុខងារណាមួយ ប្រសិនបើមានបញ្ហាបច្ចេកទេសណាមួយកើតឡើង ដែលអាចមានផលប៉ះពាល់ដល់ប្រព័ន្ធធនាគារ ឬ ក្នុងគោលបំណងថែទាំប្រព័ន្ធ ឬ ផ្សេងៗ។

16.8. ប្រសិនបើប័ណ្ណរបស់លោក-លោកស្រី មិនអាចប្រើប្រាស់បានដោយករណីប្រធានសក្តិ ខេប៊ីប្រាសាក់ នឹងជួយដល់ លោក-លោកស្រី ក្នុងការរកដំណោះស្រាយ ឬ ផ្តល់ជំនួយការចាំបាច់ណាមួយយោងលើហេតុផលជាក់ស្តែង ប៉ុន្តែខេប៊ីប្រាសាក់មិនទទួលខុសត្រូវទៅលើហេតុការណ៍ទាំងនោះទេ។

16.9. ខេប៊ីប្រាសាក់រក្សាសិទ្ធិក្នុងការផ្អាកប្រតិបត្តិការពេលមានបញ្ហាផ្សេងៗ និងពេលមានការចាំបាច់ជាដើម។

16.10. ខេប៊ីប្រាសាក់រក្សាសិទ្ធិក្នុងការដោះស្រាយបញ្ហាជូនលោក-លោកស្រី ដោយអនុលោមតាមច្បាប់ និង/ឬ គោលការណ៍របស់ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង/ឬ ខេប៊ីប្រាសាក់ និង/ឬ ស្ថាប័នទូទាត់អន្តរជាតិ (វីសា ឬ ផ្សេងៗ)។

17. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

- អនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ខេប៊ីប្រាសាក់ អាចនឹងពន្យារពេល ឬ មិនធ្វើប្រតិបត្តិការជូន លោក-លោកស្រី ប្រសិនបើ ខេប៊ីប្រាសាក់ មានការជឿជាក់ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖
  1). ខេប៊ីប្រាសាក់ មានការសង្ស័យចំពោះប្រភពដើមនៃប្រាក់ ឬ ប្រតិបត្តិការនោះ
  2). ប្រតិបត្តិការ ឬ គណនីនោះមានទំនាក់ទំនង ឬ ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលជាមួយនឹងសកម្មភាពល្មើសច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់អន្តរជាតិ
  3). មានការបង្គាប់បញ្ជាពីតុលាការ ឬ ធនាគារជាតិ នៃ កម្ពុជា។ល។

18. ការដោះស្រាយវិវាទ

18.1. អតិថិជន មានរយៈពេល **30ថ្ងៃ** បន្ទាប់ពីថ្ងៃធ្វើប្រតិបត្តិការ សម្រាប់ដាក់បណ្តឹងពាក់ព័ន្ធនឹងប្រតិបត្តិការប័ណ្ណដែលមានវិវាទរួមមាន៖
- ប្រតិបត្តិការគ្មានការអនុញ្ញាត ឬ
- ប្រតិបត្តិការស្ងួន ឬ
- ប្រតិបត្តិការបន្លំ បោកប្រាស់ ឆបោក ឬ
- ប្រតិបត្តិការខុសចំនួនទឹកប្រាក់ ឬ
- ប្រតិបត្តិការខុសរូបិយប័ណ្ណ និង/ឬ
- ប្រតិបត្តិការផ្សេងៗដែលពាក់ព័ន្ធនឹងការទូទាត់ដោយប័ណ្ណ។

18.2. អតិថិជន អាចដាក់បណ្តឹងតាមរយៈទូរស័ព្ទមក **មន្ត្រីទំនាក់ទំនងអតិថិជន** (Call Center) ឬ ស្នើសុំជាលាយលក្ខណ៍អក្សរនៅសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត ដោយផ្តល់ព័ត៌មានពាក់ព័ន្ធនឹងគណនី ប័ណ្ណ ប្រតិបត្តិការ និង/ឬ ផ្តល់ឯកសារគាំទ្រតាមការស្នើសុំពីខេប៊ីប្រាសាក់។

19. ច្បាប់គ្រប់គ្រង

- លក្ខខណ្ឌប្រើប្រាស់នេះ ត្រូវបានគ្រប់គ្រង និងបកស្រាយដោយយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

20. វិភាគភាព

- ប្រសិនបើប្រការណាមួយនៃលក្ខខណ្ឌប្រើប្រាស់នេះ មិនអាចអនុវត្តបាន ឬ គ្មានសុពលភាពតាមផ្លូវច្បាប់ ប្រការទាំងនោះនឹងអស់សុពលភាពត្រឹមកម្រិតដែលប្រការនោះមិនអាចអនុវត្តបាន ឬ អសុពលភាពនៃប្រការនោះតែប៉ុណ្ណោះ ចំណែកប្រការផ្សេងៗទៀតនៃលក្ខខណ្ឌប្រើប្រាស់នេះនៅតែបន្តមានសុពលភាពអនុវត្តដដែល។

21. ភាសា

- លក្ខខណ្ឌប្រើប្រាស់នេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ និងអង់គ្លេស។ ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរមានន័យមិនស្រប ឬ មិនស៊ីគ្នា នោះអត្ថបទជាភាសាខ្មែរចាត់ទុកជាផ្លូវការ៕

ចប់